អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



# ផ្ទះរបស់សុខា

## Sokha's House

Written by TukTuk

Illustrated by Kaho Yamada

សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Kaho Yamada

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ១



ជម្រាបសួរ! ខ្ញុំឈ្មោះសុខា។ ខ្ញុំនឹងប្រាប់អ្នកអំពីផ្ទះរបស់ខ្ញុំ!
តើអ្នកឃើញផ្ទះមួយនៅពីក្រោយខ្ញុំទេ? នោះជាផ្ទះរបស់ខ្ញុំ។



# ២



នៅផ្ទះរបស់ខ្ញុំមានដើមដូង។
តើមានដើមដូងចំនួនប៉ុន្មាន? ១ ២! មាន២ដើម។
នៅពេលដែលខ្ញុំស្រេកទឹក បងប្រុសច្បងរបស់ខ្ញុំនឹងឡើងទៅបេះដូងឱ្យខ្ញុំផឹក។

# ៣



នៅពីមុខផ្ទះរបស់ខ្ញុំ មានពាងទឹក។
តើមានពាងទឹកចំនួនប៉ុន្មាន? ១ ២ ៣! មាន៣។
ពួកយើងប្រើប្រាស់វា នៅពេលដែលពួកយើងងូតទឹក ចម្អិនអាហារនិងធ្វើអ្វីផ្សេងទៀត។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ៤



មើលនំ! នៅជុំវិញពាងទឹកមានកូនឆ្កែ។
តើមានកូនឆ្កែចំនួនប៉ុន្មាន? ១ ២ ៣ ៤! មាន៤ក្បាល។
ពួកវាទើបតែកើតកាលពីខែមុនទេ។ តើពួកវាស្អាតដែរទេ?

# ៥



មើលទៅនុ៎ះ! មានកូនមាន់ទៀតផង។
តើមានកូនមាន់ចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥! មាន៥ក្បាល។
ចេបៗ ចេបៗ ចេបៗ! តើម៉ែនៅទីណា? កូនមាន់កំពុងតែរកមេរបស់ពួកវា។

# ៦



តើអ្នកឃ្លានមែនទេ? កុំបារម្ភអីណា! ពួកយើងមានដើមស្វាយចំនួន១ដើម។
តោះទៅមើលថា តើមានផ្លែស្វាយចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?
តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦! មាន៦ផ្លែ។




ពួកយើងថែមទាំងមានដើមចេកចំនួន១ដើមទៀតផង។
តើមានផ្លែចេកចំនួនប៉ុន្មានផ្លែដែលយើងអាចញ៉ាំបាន?
តោះរាប់ជាមួយគ្នា ១ ២ ៣ ៤ ៥ ៦ ៧! មាន៧ផ្លែ។




ម៉ែនៅទីនេះ! គាត់ត្រឡប់មកពីធ្វើការវិញហើយ។ គាត់មានហាងលក់ចេកចៀនមួយ។
ថ្ងៃនេះ គ្រប់គ្នានឹងមកលេងពួកយើង ដូច្នេះគាត់បានយកចេកចៀនខ្លះៗមកផ្ទះ។
តើមានចេកចៀនចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨! យ៉េ! មាន៨ដុិ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ៩



លោកយាយបានមកដល់ផ្ទះ! សួស្តីសុខា! តើចៅចូលចិត្តនំអន្សមមែនទេ?
លោកយាយបានទិញនំអន្សមផ្ញើចៅ។ យ៉េ! អរគុណលោកយាយ។
តើមាននំអន្សមចំនួនប៉ុន្មាន? ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩! មាន៩នំ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# ១០



ថ្ងៃនេះ គ្រួសាររបស់ខ្ញុំបានមកជួបជុំគ្នា។ លោកយាយនិងលោកតា ម៉ាក់និងប៉ា បងស្រីនិងបងប្រុស
ខ្ញុំនិងប្អូនប្រុសពៅ ហើយបន្ទាប់មកគឺបងប្អូនជីដូនមួយចំនួនពីរនាក់ទៀត។
តើទាំងអស់គ្នាមានចំនួនប៉ុន្មាននាក់? ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០! មានចំនួន ១០នាក់។
ពួកយើងញ៉ាំអាហារពេលល្ងាចជុំគ្នាយ៉ាងសប្បាយរីករាយ។